# កិច្ចព្រមព្រៀងគម្រោងការ

រវាង

ក្រសួងអប់រំ យុវជន និងកីឡា
នៃព្រះរាជាណាចក្រកម្ពុជា

និង

អង្គការ KIDSHELP KAMBODSCHA E.V

# សង្ខេបគម្រោងកម្មវិធី

- **ឈ្មោះគម្រោង៖** ការអប់រំសម្រាប់អនាគតដ៏ភ្លឺស្វាង
- **ស្ថាប័នអនុវត្តគម្រោង៖** អង្គការ Kidshelp Kambodscha e.V
- **អ្នកផ្តល់ជំនួយសំខាន់ៗ៖** អង្គការ Kidshelp Kambodscha e.V អាឡឺម៉ង់ អង់គ្លេស
- **ទីកន្លែងអនុវត្តគម្រោង៖** ឃុំព្រែកដំបង និងឃុំរកាកោង២ ស្រុកមុខកំពូល និងឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងរាជធានីភ្នំពេញ
- **អាសយដ្ឋាន៖** ផ្លូវជាតិលេខ៦A ភូមិឡុឥដ្ឋ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល លេខទូរស័ព្ទ ០៧៧ ២១០ ៣២២ អ៊ីមែល Khemara.khath@gmail.com
- **រយៈពេលគម្រោង៖** ៣ឆ្នាំ
- **ថវិកាសរុបសម្រាប់គម្រោង៖** ៣២៩,៦០០ ដុល្លារអាមេរិក
- **ចំនួនបុគ្គលិកខ្មែរបម្រើការក្នុងគម្រោង៖** ០៣នាក់
- **គោលដៅទូទៅនៃកិច្ចសហប្រតិបត្តិការ និង ជំនួយការក្នុងគម្រោង ៖**

១. ការលើកកម្ពស់លទ្ធភាពទទួលបាន និងលើកកម្ពស់គុណភាពនៃការអប់រំរបស់កុមារ និងយុវជនមកពីគ្រួសារក្រីក្រ។

២. ការពង្រឹងប្រព័ន្ធគ្រប់គ្រងការអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីបង្កើនការលើកកម្ពស់លទ្ធភាពទទួលបាន និងគុណភាពនៃការអប់រំរបស់កុមារជាពិសេសក្រុមជួបការលំបាក និងខ្វះខាត។

# ពណ៌នាពីកម្មវិធីគម្រោង

អង្គការ Kidshelp Kambodscha e.V ចង់ជួយពង្រឹងប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា និងធ្វើឱ្យមានការអប់រំបានទៅដល់កុមារដែលមិនមានលទ្ធភាពសិក្សា។ កុមារដែលចូលរួមកម្មវិធីរបស់ពួកយើងនឹងអាចទទួលបានការឧបត្ថម្ភចាប់ពីឆ្នាំទីមួយរហូតដល់បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ។

១. សាវតារគម្រោង

កុមារជាច្រើននៅតាមជនបទត្រូវបានឈប់រៀនព្រោះតែត្រូវជួយធ្វើការងារឪពុកម្តាយរបស់ពួកគេហើយការឧបត្ថម្ភផ្ទាល់ខ្លួនរបស់យើងបានបញ្ជាក់ច្បាស់ថាពួកគេ នឹងអាចបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យដោយជោគជ័យ។ ក្នុងករណីជាច្រើនចំពោះការអប់រំក្នុងសាលារដ្ឋគឺមិនទាន់គ្រប់គ្រាន់សម្រាប់កុមារដើម្បីអាចសិក្សានៅសាកលវិទ្យាល័យ និងមិនអាចឱ្យពួកគេជោគជ័យក្នុងសង្គមសព្វថ្ងៃបានទេ។ ដោយមូលហេតុនេះហើយ

ទើបយើងបន្ថែមថ្នាក់សិក្សាជាច្រើនទៀត ដូចជាថ្នាក់ភាសាអង់គ្លេស ថ្នាក់កុំព្យូទ័រ និងវគ្គបណ្តុះបណ្តាលជាច្រើនទៀត ក្នុងសាលារៀនរបស់យើង។ សិស្សណាដែលបានបញ្ចប់ការសិក្សានៅវិទ្យាល័យដោយជោគជ័យតែងតែមិនមានលទ្ធភាពបន្តការសិក្សានៅសាកលវិទ្យាល័យ និងពួកគេមានបញ្ហាក្នុងការជ្រើសមុខវិជ្ជាដើម្បីសិក្សាដូច្នេះយើងបានផ្តល់អាហារូបករណ៍ និងការជួយណែនាំជាច្រើនដល់ពួកគេ។

## ២. គោលដៅ និងបេសកកម្ម

នៅអង្គការ Kidshelp Kambodscha e.V យើងជឿជាក់ថាការអប់រំគឺជាវិធីដ៏ល្អបំផុតក្នុងការផ្លាស់ប្តូរអនាគតមនុស្សជំនាន់ក្រោយរបស់កម្ពុជា។ គម្រោងរបស់ពួកយើងតាំងចិត្តជួយកុមារក្រីក្រទាំងអស់ក្នុងប្រទេសកម្ពុជាឱ្យមានការផ្លាស់ប្តូរដើម្បីទទួលបានការអប់រំល្អ។ ទាំងអស់នេះនឹងអាចជួយពួកគេឱ្យមានជំហរខ្លួនឯងបាន និងអាចមើលថែខ្លួនឯង និងអ្នកដទៃទៀត។ យើងអាចជួយពួកគេតាំងពីថ្នាក់ទីមួយរហូតដល់ថ្នាក់វិទ្យាល័យ។ យើងក៏មានទំនាក់ទំនងជាមួយក្រុមហ៊ុនជាច្រើនក្នុងទីក្រុងភ្នំពេញ ដើម្បីឱ្យពួកគេរៀនអំពីការងារ និងអាចទទួលបានការងារផងដែរ។

យើងចង់បំពេញសមត្ថភាពមនុស្សវ័យក្មេងឱ្យបានគ្រប់គ្រាន់ចំពោះអ្នកដែលមិនអាចជួយខ្លួនឯងបាន ប៉ុន្តែពួកគេក៏ត្រូវចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមកម្ពុជាផងដែរ។

## ៣. វិសាលភាពគម្រោង

ទីតាំងសកម្មភាពរបស់ពួកយើង គឺធ្វើការផ្តោតសំខាន់នៅក្នុងខេត្តកណ្តាល ក្នុងឃុំព្រែកដំបង ឃុំកោះកោង២ ឃុំព្រែកតាមាក់ និងផ្ទះនិស្សិតសម្រាប់សិស្សដែលត្រូវបន្តការសិក្សានៅតាមសាកលវិទ្យាល័យ ក្នុងទីក្រុងភ្នំពេញផងដែរ។

## ៤. សកម្មភាព

យើងបានជួយកុមារចំនួន២៦០នាក់ដែលម្នាក់ៗមានម្ចាស់ជំនួយផ្ទាល់ខ្លួនហើយសិស្សទាំងអស់ត្រូវតែមករៀនឱ្យបានទៀងទាត់ពេលវេលា។ នេះគឺដើម្បីបញ្ជាក់ថា ពួកគេមានវត្តមានទៀងទាត់ក្នុងថ្នាក់រៀន ហើយកុមារមិនចាំបាច់ត្រូវជួយកិច្ចការឪពុកម្តាយនៅផ្ទះ ឬនៅតាមវាលស្រែនោះឡើយ។ ពួកគេទាំងអស់អាចចូលរៀនសាលារបស់ពួកយើងដែលមានឈ្មោះថា Khemara Kidshelp School ដែលមានបង្រៀនភាសាអង់គ្លេស និងកុំព្យូទ័រ។ ពេលខ្លះយើងក៏បានបន្ថែមថ្នាក់ដូចជាថ្នាក់ការពារបរិស្ថាន ថ្នាក់សង្គ្រោះបឋម និងថ្នាក់ថែទាំសុខភាពមាត់ធ្មេញ។ល។ កូនសិស្សដែលចង់ទៅបន្តការសិក្សានៅសាកលវិទ្យាល័យនឹងអាចទទួលបានព័ត៌មានទាំងអស់អំពីសាកលវិទ្យាល័យផ្សេងៗគ្នា និងការសិក្សាជំនាញជាច្រើនក្នុងទីក្រុងភ្នំពេញ។ ប្រសិនបើពួកគេអាចសិក្សាបានយើងនឹងផ្តល់អាហារូបករណ៍ និងកន្លែងស្នាក់នៅដល់ពួកគេ។ ក្នុងផ្ទះនិស្សិតរបស់ពួកយើង និស្សិតអាចទទួលបានអ្នកជំនួយការក្នុងការសិក្សា និងមធ្យោបាយងាយស្រួលជាច្រើនដែលមានសារៈសំខាន់ក្នុងការសិក្សាដើម្បីឱ្យពួកគេអាចទទួលបានជោគជ័យ។

## ៥. ក្រុមគោលដៅ ឬអ្នកទទួលផល

គម្រោងរបស់ពួកយើងគឺសំដៅលើអ្នកមិនបានចូលសាលារៀន និងសិស្សសាកលវិទ្យាល័យគ្រប់អាយុទាំងអស់នៅជនបទ។ លក្ខខណ្ឌនេះគឺ សំដៅលើអ្នកដែលមិនមានលទ្ធភាពចំណាយលើការអប់រំល្អសម្រាប់ខ្លួនឯងប៉ុន្តែពួកគេមានឆន្ទៈ និងមានសមត្ថភាពក្នុងការសិក្សាបន្ត។ ក្នុងករណីដ៏ពិសេសនេះ យើងជួយឧបត្ថម្ភ និងណែនាំពួកគេតាំងពីឆ្នាំទីមួយរហូតដល់បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ និងអាចចាប់ផ្តើមធ្វើការងារប្រកបដោយវិជ្ជាជីវៈ។

# លក្ខខណ្ឌលម្អិតនៃកិច្ចព្រមព្រៀង

**រវាង ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា**

**និង**

**អង្គការ** Kidshelp Kambodscha e.V

**បានព្រមព្រៀងដូចខាងក្រោមនេះ ៖**

## មាត្រា១

## លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

១.១ កិច្ចព្រមព្រៀងនេះ គឺធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ Kidshelp Kambodscha e.V ទាំងការអនុវត្ត និងការវាយតម្លៃលើសកម្មភាពទាំងមូលរបស់គម្រោង ដើម្បីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា។

១.២ រាល់ការអនុវត្តគម្រោងត្រូវបានពិភាក្សាជាមួយមន្ទីរជំនាញថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

១.៣ រាល់ការជួសជុល ឬសាងសង់សំណង់ណាមួយត្រូវធ្វើការពិភាក្សាល្អិតល្អន់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិនទើបអាចដំណើរការបាន។ រាល់គម្រោង និងប្លង់សាងសង់រួមទាំងក្បាច់រចនាត្រូវធ្វើឡើងឱ្យស្របតាមការណែនាំរបស់ក្រសួងជំនាញ។

១.៤ កាលបរិច្ឆេទគម្រោងចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៦ ហើយនឹងបន្តរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៨។

១.៥ ក្នុងភាពជាដៃគូការងារក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ Kidshelp Kambodscha e.V បានឯកភាពគ្នាថានឹងធ្វើការពិនិត្យឡើងវិញលើគម្រោងយ៉ាងតិច៣ខែមុនកាលបរិច្ឆេទបញ្ចប់នៃគម្រោង។ ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នារួចហើយសេចក្តីសម្រេចរួមគ្នានឹងត្រូវធ្វើឡើងថាតើត្រូវបញ្ចប់គម្រោងតាមពេលកំណត់ ឬក៏ស្វែងរកកិច្ចបន្តគម្រោងនេះមួយរយៈបន្ថែមទៀត។

១.៦ កិច្ចព្រមព្រៀងនេះ ត្រូវបានប្រើប្រាស់ជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ Kidshelp Kambodscha e.V សម្រាប់ជាមូលដ្ឋានក្នុងការធ្វើកិច្ចសហប្រតិបត្តិការក្នុងការងារ។

## មាត្រា២

### **អង្គការ** Kidshelp Kambodscha e.V **បានព្រមព្រៀង**

២.១ គោរពតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងគោរពទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនកម្ពុជា។

២.២ អនុវត្តការងារ ដើម្បីសម្រេចនូវទិសដៅគម្រោងជាក់លាក់ដូចខាងក្រោម៖

ក. ពង្រីកដំណើរការ និងពង្រឹងគុណភាពការមើលថែរក្សាកុមារតូចៗ និងកម្មវិធីអភិវឌ្ឍន៍សម្រាប់កុមារក្រោមអាយុ៦ឆ្នាំ។

ខ. កែលម្អដំណើរការ និងបង្កើនគុណភាពនៃការអប់រំកម្រិតបឋមសិក្សា និងការអប់រំកម្រិតមធ្យមសិក្សា។

គ. ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការគាំទ្រលើការកែលម្អដំណើរការ និងគុណភាពអប់រំសម្រាប់កុមារ ជាពិសេសគុណវិបត្តិដែលកុមារបាត់បង់ឱកាសក្នុងការសិក្សា។

២.៣ ធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ដែលជាដៃគូការងារដើម្បីទទួលបានលទ្ធផលល្អកម្រិតអតិបរមាក្នុងការផ្ទេរបច្ចេកទេស និងសមត្ថភាពគ្រប់គ្រង និងធ្វើផែនការដល់មន្ត្រីរាជការក្រសួង។

២.៤ រាល់ការបោះពុម្ពឬឯកសារទាំងឡាយណាដែលបានមកពីសមិទ្ធផលរបស់គម្រោងនេះ ត្រូវដាក់ជូនក្រសួងផ្តល់យោបល់ រួចហើយនឹងត្រូវចាត់ទុកជាសម្បត្តិរួមគ្នារបស់អង្គការ Kidshelp Kambodscha e.V និងក្រសួងអប់រំ យុវជន និងកីឡា។

២.៥ ចូលរួមឱ្យបានទៀងទាត់នៅរាល់កិច្ចការប្រជុំនីមួយៗ តាមការអញ្ជើញរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោងដែលកំពុងដំណើរការ ព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាដើម្បីឈានទៅសម្រេចជោគជ័យតាមទិសដៅរបស់គម្រោង។

២.៦ គម្រោងថវិកាដែលបានអនុម័ត ត្រូវប្រើប្រាស់ឱ្យមានប្រសិទ្ធភាពតាមទិសដៅដូចបានកំណត់៖

## គម្រោងថវិកាសម្រាប់រយៈពេលបីឆ្នាំ

| គម្រោងចំណាយថវិកា (គិតជាដុល្លារ) | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | សរុប |
|---|---|---|---|---|
| ការឧបត្ថម្ភរបស់កុមារ | ៤១,០០០ | ៤១,០០០ | ៤១,០០០ | ១២៣,០០០ |
| ជំនួយបន្ថែមសម្រាប់កុមារដែលបានឧបត្ថម្ភ | ២,០០០ | ២,០០០ | ២,០០០ | ៦,០០០ |
| ការឧបត្ថម្ភនិស្សិតសាកលវិទ្យាល័យ | ៣៨,០០០ | ៣៩,០០០ | ៤០,០០០ | ១១៧,០០០ |
| ការចំណាយរបស់សាលា(អាហារូបករណ៍សាលា ការសម្អាត អ្នកស្ម័គ្រចិត្ត ការជូសជុល។ល។) | ៩,៩០០ | ៩,២០០ | ៩,២០០ | ២៨,៣០០ |
| មធ្យោបាយដឹកជញ្ជូន | ១,០០០ | ១,០០០ | ១,០០០ | ៣,០០០ |
| ការចំណាយលើការិយាល័យ និងការផ្គត់ផ្គង់ (ប្រៃសណីយ៍ វិក័យប័ត្រទូរសព្ទ។ល។) | ១,០០០ | ១,០០០ | ១,០០០ | ៣,០០០ |
| ប្រាក់បៀវត្សរ៍ | ១៤,៥០០ | ១៥,៥០០ | ១៥,៥០០ | ៤៥,៥០០ |
| ការចំណាយលើអ្នកគ្រប់គ្រងផ្សេងទៀត (ការចុះឈ្មោះពន្ធដារ ទិដ្ឋាការ។ល។) | ១,៤០០ | ១,២០០ | ១,២០០ | ៣,៨០០ |
| **ចំណាយសរុបក្នុងមួយឆ្នាំ** | **១០៨,៨០០** | **១០៩,៩០០** | **១១០,៩០០** | **៣២៩,៦០០** |

២.៧ ផ្តល់ជូនក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានជំនាញ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ពាក់ព័ន្ធ) នូវរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយផ្អែកលើប្រតិទិនប្រចាំឆ្នាំ រួមមានៈ

-របាយករណ៍សកម្មភាព និងការរីកចម្រើនរបស់គម្រោង

-បញ្ហានានាដែលពាក់ព័ន្ធនឹងការអនុវត្តរបស់គម្រោង

-ចំណាយថវិកាគម្រោង (តាមប្រភេទដូចបានចែងក្នុងតារាងខាងលើ) និង

-ព័ត៌មានស្តីពីចំនួនបុគ្គលិកបរទេស និងបុគ្គលិកជាតិ ព្រមទាំងតួនាទីរបស់ពួកគេ។

## មាត្រា ៣
## ក្រសួងអប់រំ យុវជន និង កីឡា ព្រមព្រៀង

៣.១ ចាត់តាំងបុគ្គលិកដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្របថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យបំពេញការងារជាមួយអង្គការ Kidshelp Kambodscha e.V ដើម្បីឱ្យសកម្មភាពគម្រោងអនុវត្តទៅមានប្រសិទ្ធភាព និងទាន់ពេលវេលា។

៣.២ អនុញ្ញាតឱ្យអង្គការ Kidshelp Kambodscha e.V អាចជួលបុគ្គលិកកម្ពុជា និងបុគ្គលិកបច្ចេកទេសអន្តរជាតិ ធ្វើការបានដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

៣.៣ សម្របសម្រួលក្នុងករណីចាំបាច់ដល់ការសុំទិដ្ឋាការឱ្យបុគ្គលិកបរទេស និងទីប្រឹក្សាអង្គការដែលចូលរួមក្នុងសកម្មភាពគម្រោងហើយត្រូវបានទទួលស្គាល់តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

៣.៤ បង្កើនប្រសិទ្ធភាព និងតម្លាភាពការងាររបស់អង្គភាពជំនាញនៅមូលដ្ឋានដែលគាំទ្រគម្រោងនេះដោយធានាយ៉ាងណាឱ្យអង្គការទទួលបានព័ត៌មានទាន់ពេលវេលាស្តីពីការប្រើប្រាស់ថវិកា និងសកម្មភាព។

៣.៥ ធានាថាក្រសួងនឹងជំរុញឱ្យមន្ទីរជំនាញថ្នាក់ក្រោមជាតិ ធ្វើការប្រាស្រ័យទាក់ទងឱ្យបានជិតស្និទ្ធជាមួយអង្គការដើម្បីកសាងផែនការ និងការគ្រប់គ្រង ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗ។

៣.៦ រាល់សំណើផ្សេងៗពីអង្គការ នឹងត្រូវបានផ្តល់ចម្លើយពីក្រសួងអប់រំ យុវជន និងកីឡា វិញជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០ថ្ងៃ (សាមសិបថ្ងៃ) បន្ទាប់ពីបានទទួលសំណើ។

## មាត្រា៤
## លក្ខខណ្ឌរួម

៤.១ នាយិការបស់អង្គការ Kidshelp Kambodscha e.V លោកស្រី ខាត់ ខេមរា នឹងត្រូវបានផ្តល់សិទ្ធិជាតំណាងអង្គការរបស់ខ្លួនដើម្បីធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

៤.២ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក និងចុះហត្ថលេខាដោយភាគីទាំងពីរ បន្ទាប់ពីបានពិចារណារួចហើយ។

៤.៣ កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ក្នុងស្ថានភាពបន្ទាន់ តាមការសម្រេចរួមគ្នាមួយរវាងតំណាងអង្គការ Kidshelp Kambodscha e.V និងក្រសួងអប់រំ យុវជន និងកីឡា ក្រោយពីបានពិគ្រោះគ្នា និងពិចារណារួចហើយ។

៤.៤ ក្រសួងអប់រំ យុវជន និង កីឡា នៃព្រះរាជាណាចក្រកម្ពុជា (នាយកដ្ឋានជំនាញ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តពាក់ព័ន្ធ) មានសិទ្ធិចុះតាមដាន និងត្រួតពិនិត្យទៅលើរាល់សកម្មភាពរបស់អង្គការ Kidshelp Kambodscha e.V។

៤.៥ អង្គការ Kidshelp Kambodscha e.V មានសិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះក្រោយពីបានពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា ប្រសិនបើពិនិត្យឃើញថាគ្មានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព ឬសុវត្ថិភាពបុគ្គលិក ឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងគ្រោះថ្នាក់ដោយសង្គ្រាម ដោយអរិភាព ឬដោយការរំខានធ្ងន់ធ្ងរណាមួយ។

៤.៦ បន្ទាប់ពីបានពិភាក្សាជាមួយអង្គការរួច ក្រសួងអប់រំ យុវជន និងកីឡា នឹងស្នើសុំឱ្យអង្គការបញ្ឈប់ការងារចំពោះបុគ្គលិកណាដែលត្រូវបានវិនិច្ឆ័យថាធ្វើឱ្យខូចកិត្តិយសរបស់ក្រសួង ឬបានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ ប្រសិនជាមានសំណើបែបនេះអង្គការ Kidshelp Kambodscha e.V ត្រូវអនុវត្តតាមដំណើរការសមគួរណាមួយ។

៤.៧ ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះប្រសិនតំណាងផ្លូវការរបស់អង្គការ Kidshelp Kambodscha e.V ត្រូវបានវិនិច្ឆ័យឃើញថាមិនបានបំពេញមាត្រា២ នៃកិច្ចព្រមព្រៀងនេះ។

៩.៨ ប្រសិនរកឃើញថាអង្គការ Kidshelp Kambodscha e.V មិនគោរពតាមច្បាប់ នៃព្រះរាជាណាចក្រ កម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា អាចបញ្ឈប់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីជូនព័ត៌មានដល់សាមីអង្គការរួចមក។

៩.៩ កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ហើយមានសុពលភាពដូចមានចែង ក្នុងចំណុច ១.៤ នៃកិច្ចព្រមព្រៀង។

*កិច្ចព្រមព្រៀងនេះ រៀបចំឡើងដោយឥតកែប្រែជាពីរភាសាគឺជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយអត្ថបទទាំងពីរភាសានេះមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខ្វែងគ្នា អត្ថបទជាភាសាខ្មែរ នឹងត្រូវបានយកជាគោល។*

ថ្ងៃ ចន្ទ ៦កើត ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៧ខែ តុលា ឆ្នាំ២០២៥

## ហត្ថលេខី

តំណាងក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

តំណាងអង្គការ KIDSHELP KAMBODSCHA E.V

លោកស្រី **ខាត់ ខេមរា**

នាយិកាប្រចាំប្រទេស